ព្រះអម្ចាស់**ប្រមូលផ្ដុំអ៊ីស្រាអែល** ( រាស្ត្ររបស់ទ្រង់ ) នៅពេលពួកគេទទួលយកទ្រង់ ហើយគោរពព្រះបញ្ញត្តិទ្រង់ ។ សូមជួយមនុស្សឲ្យឆ្លងកាត់ទីខ្វាត់ខ្វែងរបស់ពួកគេ ដើម្បីពួកគេអាចជួបនឹងព្រះយេស៊ូវបាន ។



**មាត្រានៃសេចក្ដីជំនឿ ១:១០**

យើងខ្ញុំជឿចំពោះការប្រមូលដ៏ពិតប្រាកដនៃសាសន៍អ៊ីស្រាអែល និងចំពោះការសាងឡើងវិញនូវពូជទាំងដប់អំបូរ ថា ក្រុងស៊ីយ៉ូន ( ក្រុងយេរូសាឡិមថ្មី ) នឹងត្រូវបានស្ថាបនានៅលើទ្វីបអាមេរិក ថាព្រះគ្រីស្ទនឹងគ្រងរាជ្យនៅលើផែនដីផ្ទាល់ ហើយថាផែនដីនឹងបានផ្លាស់ប្ដូរសារជាថ្មី ហើយនឹងទទួលសិរីល្អដ៏ប្រកបដោយភាពបរមសុខ ។